ការសម្លាប់អ្នកសារព័ត៌មាននៅក្នុងឆ្នាំ ១៩៩៣




**១៩៩៤**

- **លោក ទូច ជាមង្គល** (១០មិថុនា) គឺជានិពន្ធនាយកប្រចាំសប្តាហ៍នៃកាសែត អន្តរាគមន៍។ គាត់ត្រូវគេរកឃើញដោយសន្លប់និងមានរបួសបាក់ឆ្អឹងតាមផ្លូវទីក្រុងភ្នំពេញ មង្គលត្រូវបានបញ្ជូនទៅមន្ទីរពេទ្យហើយបាន ស្លាប់នៅថ្ងៃបន្ទាប់ (១១មិថុនា)។ មិនមានមូលហេតុច្បាស់លាស់ឡើយចំពោះការស្លាប់របស់គាត់ ប៉ូលីសបានអះអាងថា គាត់ជាជនគ្រោះនៃឧបទ្ទវហេតុចរាចណ៍ (របាយការណ៍មួយបានបញ្ជាក់ថា ប៉ូលីសបានរាយការណ៍អំពីមូលហេតុនៃការ ស្លាប់នេះថា ជាករណីម៉ូតូបុកជាមួយនឹងឡានតាក់ស៊ី)។ ទោះបីជាយ៉ាងណាក៏ដោយមានការស៊ើបអង្កេតមួយបានបង្ហាញ ថាវាមិនអាចទៅរួចទេដែលថាខ្លួនរបស់គាត់បានបុកយ៉ាងខ្លាំងនិងគ្មានរបួសផ្សេងទៀតនោះ ហើយម៉ូតូរបស់គាត់មិនមាន ការខូចខាតនោះ។ អន្តរាគមន៍ ធ្លាប់បានចេញនូវអត្ថបទមួយដែលទាក់ទងនឹងអំពើពុករលួយរបស់រដ្ឋាភិបាលនិងមន្ត្រី យោធា។ មានរបាយការណ៍មួយចំនួនបានបង្ហាញថាការស្លាប់របស់មង្គលនេះគឺមានជាប់ទាក់ទងទៅនឹងអត្ថបទទាំងនោះ ហើយគ្មានអ្នកណាម្នាក់ត្រូវបានចាប់ខ្លួននោះទេទាក់ទងនឹងការស្លាប់របស់មង្គល។

- **លោក នួន ចាន់** (៦កញ្ញា) -នួន ចាន់ គឺជានិពន្ធនាយក នៃកាសែត សម្លេងយុវជនខ្មែរ ត្រូវបានបាញ់សម្លាប់ដោយខ្មាន់កាំភ្លើងមិនស្គាល់មុខ ពីរនាក់នៅចំកណ្តាលរាជធានីភ្នំពេញ។ រដ្ឋាភិបាលបានថ្កោលទោសចំពោះការសម្លាប់នេះ តែបានព្រមានថា "មានកាសែតក្នុងស្រុកមួយចំនួន បានចុះផ្សាយជាច្រើនដងទាក់ទងទៅនឹងអត្ថបទចោទប្រកាន់គ្មាន ហេតុផលទៅកាន់មេដឹកនាំរដ្ឋាភិបាល បុគ្គលផ្សេងទៀត និង មន្ត្រីមួយចំនួនទៀតថាជាប់ទាក់ទងនិងបញ្ហានេះបញ្ហានោះ"។ នៅក្នុងខែ កញ្ញា ប៉ូលីសបានធ្វើការចាប់ខ្លួនជនសង្ស័យពីរនាក់ ប៉ុន្តែចៅក្រមស៊ើបអង្កេតបានចេញសេចក្តីថ្លែងការណ៍មិនយល់ព្រមអំពីការសារភាពរបស់នៃជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យទាំងពីរដែលត្រូវបានបង្ខិតបង្ខំ ហើយស្នើរសុំអោយមានការស៊ើបអង្កេតបន្ថែមទៀត។ សេចក្តីថ្លែងការណ៍មួយបានធ្វើការរិះគន់ចំពោះអាជ្ញាធររដ្ឋាភិបាលនិងបានចុះផ្សាយនូវអត្ថបទអំពីមន្ត្រីរដ្ឋាភិបាលជាប់ទាក់ទងជាមួយអំពើពុករលួយ។ នួន ចាន់ បានទទួលការហាមឃាត់ជាច្រើនដង និងការគំរាមកំហែងសម្លាប់អនាមិកនៃការគ្របដណ្តប់របស់គាត់ទាក់ទងនឹងអំពើពុរលួយនៃរដ្ឋាភិបាល។
- **លោក ចាន់ ដារា** (៨ធ្នូ) -ចាន់ ដារា គឺជាអ្នកកាសែតនៃកាសែតជាភាសាខ្មែរ កោះសន្តិភាពនិងសារព័តមានដទៃទៀតដែរ គាត់ត្រូវបានគេបាញ់សម្លាប់នៅភាគខាងកើត ខេត្តកំពង់ចាម ជាកន្លែងដែលគាត់ផឹកជាមួយលោកវីរសេនីយឯក សាត់សឿន។ គាត់ត្រូវបានគេបាញ់ចំនួនពីរគ្រាប់ត្រង់ខ្នង ក្រោយពីការបាញ់ ប៉ូលីសបានធ្វើការសន្និដ្ឋាន ជនល្មើសបានប្រើកាំភ្លើងខ្លី K59 (9mm) និងធ្វើការលបបាញ់ចម្ងាញ១ម៉ែត្រពីជនរងគ្រោះ។ ក្រសួងមហាផ្ទៃបានធ្វើការ ចាប់ខ្លួនលោកវីរសេនីយឯក សាត់សឿន ដែលបានធ្វើរលិខិតគំរាមកំហែងពីរ ទៅកាន់កាសែត (កោះសន្តិភាព និង ព្រាបនាំសារ) និងកិរិយារបស់លោក ចាន់ ដារា។ ទោះបីជាយ៉ាងណាក៏ដោយលោកវីរសេនីយឯកត្រូវបានដោះលែងវិញ នៅក្នុងខែ ឧសភា ឆ្នាំ១៩៩៥ បន្ទាប់តុលាការខេត្តដោះលែងគាត់ដោយសារគ្មានភ័ត្តុតាងគ្រប់គ្រាន់ដើម្បីធ្វើការចោទ ប្រកាន់។

**១៩៩៦**

- **លោក ធន់ ប៊ុនលី** (១៨ ឧសភា) ធន់ ប៊ុនលី គឺជាអ្នកសសេរសៀវភៅ និងជាអតីតអ្នកបោះពុម្ពផ្សាយនៃកាសែតប្រឆាំងឧត្តមគតិខ្មែរ។ គាត់ក៏ជាអ្នកគាំទ្រដែលលេចធ្លោមួយរូបរបស់គណបក្ស សមរង្ស៊ី សញ្ញាតិខ្មែរផងដែរ។ គាត់បានចេញពីផ្ទះរបស់គាត់ក្នុងទីក្រុងភ្នំពេញនៅម៉ោង ១០និង៣០នាទីព្រឹក និងបានហៅម៉ូតូឌុប។ ម៉ូតូបានបើកទៅផ្លូវ៩៥ ហើយមានម៉ូតូមួយផ្សេងទៀតជិះដោយបុរសពីរនាក់ ដោយម្នាក់ជាអ្នកបើក និងម្នាក់ទៀតជាអ្នបាញ់ ធន់ ប៊ុនលី ចំនួនពីរគ្រាប់ត្រូវ ចំទ្រូង និង គ្រាប់ទីបីត្រង់ដៃខាងឆ្វេង គាត់បានដួលធ្លាក់ទៅក្រោមហើយអ្នករត់ម៉ូតូឌុបបានជិះទៅបាត់។ យោងទៅតាមរបាយការណ៍មួយរបស់អង្គការលើកលែងទោសអន្តរជាតិ ប៉ូលីសបានទៅវត្តដែលជាកន្លែងតំកល់សពគាត់ និងបានកាយយកគ្រាប់កាំភ្លើងចេញពីសាកសពរបស់គាត់។ នេះគឺជាការបំបិទនូវភ័ស្តុតាង ហើយក៏គ្មានអ្នកណាម្នាក់ត្រូវបានចាប់យកខ្លួន ក៏ដូចជាយកមកកាត់ទោសឡើយ។ មុនពេលការស្លាប់របស់លោក ធន់ ប៊ុនលី ត្រូវបានចោទពីបទបរិហាកេរ្តិ៍ និងផ្សាយព័តមានមិនពិតសម្រាប់រិះគន់រដ្ឋាភិបាល នៅក្នុងអត្ថបទ លិខិត និងរូបថ្លុកផ្សេងៗ។

១៩៩៧

- **លោក ចិត្រ ដួងដារ៉ាវុទ្ធ** (៣០មិនា) ចិត្រ ដួងដារ៉ាវុទ្ធ គឺជាអ្នកកាសែតនៃ កាសែតអ្នកប្រយុទ្ធ។ គាត់ត្រូវបានគេសម្លាប់ក្នុង ការបំផ្ទុះគ្រាប់បែកដៃនៅថ្ងៃ ទី៣០ មិនា ឆ្នាំ ១៩៩៧ ខណៈដែលពេលដែលគាត់កំពុងរងចាំយកព័តមានពីការប្រជុំនៃ គណបក្សសញ្ញាតិខ្មែរនៅខាងក្រៅរដ្ឋសភាជាតិ ដែលជាកន្លែងដែលលោកប្រធានគណបក្សប្រឆាំង សម រង្ស៊ី កំពុងនិយយ។ មានសាក្សីជាច្រើនបានប្រាប់ថាមានគ្រាប់បែកចំនួន៤គ្រាប់ត្រូវបានបោះចូលទៅក្នុងហ្វូងមនុស្ស។ យោងទៅតាមរបាយការណ៍សិទ្ធមនុស្សរបស់អង្គការ លីកាដូក្នុងឆ្នាំ ២០០៤ មានមនុស្សចំនួន១២នាក់បានស្លាប់ និង ២០០នាក់ទៀតរងរបួស។ មានសាក្សីជាច្រើនបានរាយការណ៍ថាកងកម្លាំងប្រដាប់អាវុធយ៉ាងច្រើន( ជាអង្គរក្សលោកហ៊ុន សែននិងកងពលតូចលេខ ៧០) បានអនុញ្ញាតអោយមនុស្សពីរនាក់គប់គ្រាប់បែកចូល។ យោងទៅតាមប្រភពរដ្ឋាភិបាល អាមេរិចដែលជារបាយការណ៍ផលិតដោយក្រុម FBI ក្នុងការបំផ្ទុះគ្រាប់បែក និងការជ្រែតជ្រែកជាបន្តបន្ទាប់ នៃកងយុទ្ធពលលេខ ៧០។ របាយការណ៍នេះក៏បានចង្អុលបង្ហាញដែរថាប៉ូលីសកម្ពុជាមានចំណេះដឹងជាមុននៃការវាយប្រហារនេះផងដែរ។
- **លោក ពេជ្រ អ៊ឹម** (៤ ឧសភា) ពេជ្រ អ៊ឹម គឺជាអ្នកបច្ចេកទសមួយរូប (ហើយក៏ជាអ្នកផ្សាយនូវរបាយការណ៍មួយចំនួនផងដែរ) នៅទូរទស្សន៍ជាតិនៅក្នុងខេត្តព្រះសីហនុ។ គាត់ត្រូវបានគេសម្លាប់ក្នុងការវាយប្រហារនៅស្ថានីយទូរទស្សន៍ មានបុរសពាក់របាំងមុខចំនួន៧នាក់ដោយប្រដាប់ដោយអាវុធ AK-47s យ៉ាងហោចណាស់គ្រាប់រ៉ាកែត B-40 ចំនួនពីរគ្រាប់បានដាក់បំបែកអាគារ។ ពេជ្រ អ៊ឹម ត្រូវបានបាញ់សម្លាប់ចំនួនពីរគ្រាប់ត្រង់ពោះ និងបានស្លាប់នៅថ្ងៃបន្ទាប់។ មនុស្សពីរនាក់ទៀតបានរងរបួសក្នុងការវាយប្រហារ និងសម្ភារៈដទៃទៀតក្នុងស្ថានីយ៍ត្រូវបានបំផ្លាញចោល។ នៅមុនថ្ងៃដែលគាត់ស្លាប់ មានការស្នើរសុំពីទៅកាន់ស្ថានីយ៍ពីសំណាក់ប៉ូលីសជាន់ខ្ពស់ក្នុងការចាក់ផ្សាយសម្លេងនៃគណបក្ស ហ៊ុនស៊ិនប៊ិចប៉ុន្តែត្រូវបានស្ថានីយ៍បដិសេធ។ គ្មានអ្នកណាម្នាក់ត្រូវបានចាប់ខ្លួនទាក់ទិននឹងហេតុការណ៍នេះទេ។
- **លោក ម៉ិចឆៀល សុខាន ដុក សុខាន** (៧កក្កដា) ម៉ិចឆៀល សុខាន កើតនៅក្នុងប្រទេសកម្ពុជា និងបានទៅរស់នៅក្នុងប្រទេសកាណាដា គាត់បានត្រលប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ ១៩៩៥ ដែលគាត់គឺជាអ្នកផ្សាយព័តមាននិងជាគ្រូបង្រៀនភាសាអង់គ្លេស នៅពេលដែលគាត់កំពុងថតយករូបភាពរបស់ទាហានលួចយករបស់របរពីផ្សារ គាត់ត្រូវបានគេទាហានម្នាក់បាញ់ចំជង្គង់ ដើម្បីជាការព្រមានក្នុងការថតរូប។ ទាហានម្នាក់នោះបានបាញ់សម្លាប់គាត់នៅចំពោះមុខភរិយានិងបងថ្លៃប្រុសរបស់គាត់ ហើយគ្មានអ្នកណាម្នាក់ត្រូវបានចាប់ខ្លួនរឺក៏ដាក់ទោសឡើយ។
- **លោក អ៊ូ សារឿន** (១៤តុលា) អ៊ូ សារឿន គឺជាអ្នកសារព័តមាននៃកាសែត សម្លេងរាស្ត្រ នៅពេលនោះគាត់បានស្លាប់កាសែតនេះត្រូវបានស៊ើបអង្កេតពីការគំរាមយកនៅផ្សារធំថ្មី ភ្នំពេញ។ហើយសន្តិសុខគឺជាគោលដៅនៃការស៊ើបអង្កេតរបស់កាសែតនោះ។ គាត់ត្រូវបានគេអូសទៅផ្លូវ ដោយគាត់បានចែកចាយកាសែតរបស់គាត់ទៅកាន់អ្នកលក់កាសែតនៅផ្សារធំថ្មីនោះនិងត្រូវបានគេបាញ់សម្លាប់។ របាយការណ៍ជាផ្លូវការមួយបានអោយដឹងថាគាត់មានជាតិស្រវឹងនិងត្រូវ បាន

សម្លាប់ដោយសារវិវាទល្បែងស៊ីសង។ សហគមន៍អ្នកកាសែតកម្ពុជាបញ្ជាក់ថា គាត់ត្រូវបានគេសម្លាប់ដោយសារការរាយការណ៍របស់កាសែតរបស់គាត់ ប៉ូលីសបានចាប់ខ្លួនសន្តិសុខដែលបានបាញ់សម្លាប់ អ៊ូ សារឿន ប៉ុន្តែគាត់ត្រូវបានគេដោះលែងវិញហើយក៏គ្មានការប្តឹងផ្តល់អ្វីទាំងអស់។

២០០៣

- **លោក ឈរ ចិត្រធារិទ្ធ** (១៨តុលា) ឈរ ចិត្រធារិទ្ធគឺជានិពន្ធនាយករងនៃស្ថានីយ៍វិទ្យុតាព្រហ្ម របស់គណបក្ស រាជានិយម ហ៊ុនស៊ិនប៉ិច តាព្រហ្មត្រូវបានស្គាល់ជាវិទ្យុរិះគន់លោកហ៊ុន សែន។ នៅម៉ោង ៨និង១៥នាទីព្រឹក ឈរ ចិត្រធារិទ្ធបាន ចតរថយន្តរបស់គាត់ចម្ងាយប្រមាណ ពីរទៅបី ម៉ែត្រពីស្ថានីយ៍វិទ្យុតាព្រហ្ម ម៉ូតូហុងដាម៉ាក សេ១២៥ មួយគ្រឿងបាន បាញ់តំរង់ពីក្រោយ។គណបក្ស សម រង្ស៊ី និង ហ៊ុនស៊ិនប៉ិច បានប្តឹងថាវាជាការវាយប្រហារផ្នែកនយោបាយ។ CCHR បានធ្វើការស៊ើបអង្កេតយ៉ាងស៊ីជម្រៅទាក់ទងនិងការសម្លាប់គឺដោយសារតែគាត់គឺជាអ្នកកាសែត។គ្មានអ្នកណាម្នាក់ត្រូវ បានចាប់ខ្លួនរឺដាក់ទោសចំពោះរឿងក្តីនេះទេ។

២០០៨

- **លោក ឃឹម សំបូរ** (១១កក្កដា) គីម សំបូរគឺជាអ្នកកាសែតនៃគណបក្សប្រឆាំងសមរង្ស៊ី មនសិការខ្មែរ គាត់បានសរសេរជា ញឹកញយអំពីការចោទប្រកាន់អំពើពុករលួយរបស់រដ្ឋាភិបាល ហើយបានធ្វើការរិះគន់យ៉ាងខ្លាំងខ្លាំងចំពោះលោក ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា។ នៅថ្ងៃទី ១១ កក្កដា ឆ្នាំ ២០០៨ គីម សំបូរ ត្រូវបានគេបាញ់បីគ្រាប់ នៅពេលដែលគាត់កំពុងបើកបរម៉ូតូជាមួនិងកូនប្រុសអាយុ ២១ឆ្នាំ ដែលត្រូវបានគេបាញ់ពីរគ្រាប់ផងដែរនៅខណៈពេលដែលគេ ស្រែកទៅកាន់សាកសពរបស់ឪពុកគេផងដែរ។ ខ្មាន់កាំភ្លើងពីររូបនេះបានប្រើកាំភ្លើងដែលគ្មានសម្លេង K-49។ គីម សំបូរ បានស្លាប់នឹងកន្លែងភ្លាមៗ ខណៈពេលដែលកូនប្រុសគាត់បានស្លាប់នៅថ្ងៃបន្ទាប់ក្រោយបញ្ជូនទៅមន្ទីរពេទ្យ។ មន្ត្រី ប៉ូលីសបាននិយាយថា ពួកគេមិនបានស្គាល់រឺឃើញអត្តសញ្ញាណរបស់ឃាតករទាំងនោះទេ។

២០១២

- **លោក ហេង សេរីឧត្តម** (៩-១១ កញ្ញា) ហេង សេរីឧត្តម គឺជាអ្នកកាសែតនៃ កាសែតវីរៈជនខ្មែរ នៅខ្មែររតនៈគីរី។ គាត់ត្រូវ បានគេស្គាល់ជាអ្នករាយការណ៍ទាក់ទងនឹងសកម្មភាពកាប់ឈើខុសច្បាប់។ ហេងសេរីឧត្តមបានរកឃើញនៅក្នុងរថយន្ត ធន់ធំរបស់គាត់ដែលគាត់ចតនៅចំការស្វាយចន្ទីនៅក្នុងខេត្តរតនៈគីរីនៃប្រទេសកម្ពុជា។ នៅថ្ងៃទី១១ ខែកញ្ញា

ឆ្នាំ២០១២ ភរិយារបស់គាត់បានរាយការណ៍ថាប្តីរបស់គាត់បានបាត់ខ្លួនបន្ទាប់ពីគាត់ត្រឡប់មកពីប្រជុំវិញ។ យោងទៅតាមសេចក្តី ថ្លែងការណ៍របស់អង្គការ លីកាដូ ក្នុងការពិនិត្យរាងកាយគាត់ឡើងវិញ ខ្លួនរបស់គាត់ត្រូវបានកាប់យ៉ាងតិចណាស៦ដង។ ករណីឃាតកម្មនេះត្រូវបានគេជឿថាជាករណីឃាតកម្មដោយចេតនាដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គាត់មិនបានបាត់ បង់ឡើយ។ ដោយហេតុករណីរនេះជាហិង្សាពីចោរ ប៉ូលីសនៃខេត្តរតនៈគីរីបានចាប់ខ្លួនមនុស្សពីរនាក់ ដោយរងការចោទ ប្រកាន់ពីរឿងក្តីឃាតកម្មរបស់លោក ហេង សេរីឧត្តម។ លោក អាន់ ប៊ុនហេង (ហៅក្រៅ អេង) និងភិរិយា ស្រឹម ស្រី (ហៅក្រៅ វី) ពួកគេទាំងពីរត្រូវបានបញ្ជូនទៅពន្ធធនាគារ ដែលអ្នកស្រី ស្រឹម ស្រីជាប់ចោទពីបទឧក្រិដ្ឋ។ នៅថ្ងៃទី២៨ សីហា ឆ្នាំ ២០១៣ តុលាការខេត្តរតនៈគីរីបានទម្លាក់ការចោទប្រកាន់ប្រឆាំងពួកគេទាំងពីរ ដោយលោក សេរី ឧត្តម ត្រូវបានសម្លាប់នៅក្នុងផ្ទះរបស់ពួកគេវិញ។